Seattle
Office of Sustainability
& Environment

## ដាក់ពាក្យសុំមូលនិធិពីកម្មវិធីជួយផ្គត់ផ្គង់សហគមន៍ Seattle’s Duwamish River Opportunity Fund

ការិយាល័យនិរន្តរភាពនិងបរិស្ថាន (OSE) របស់ទីក្រុង Seattle មានសេចក្ដីរំភើបរីករាយក្នុងការប្រកាសថាកម្មវិធីមូលនិធិជួយផ្គត់ផ្គង់សហគមន៍ Duwamish River Opportunity Fund **ឥឡូវនេះកំពុងទទួលយកពាក្យសុំជំនួយ។** ឆ្នាំនេះ មានប្រាក់ចំនួន $240,000 សម្រាប់ផ្ដល់ជំនួយរហូតដល់ទៅ $40,000 ដើម្បីគាំទ្រគម្រោងការដែលនឹងកើតឡើងនៅក្នុងឆ្នាំ 2024។ មូលនិធិទាំងនេះគឺដើម្បីគាំទ្រដល់គម្រោងការនិងកម្មវិធីដែលដឹកនាំដោយសហគមន៍ដែលលើកកម្ពស់គុណភាពនៃជីវិតនៅក្នុងតំបន់ស្ទឹង Duwamish ។ **ថ្ងៃផុតកំណត់នៃការដាក់ពាក្យសុំគឺ ម៉ោង 5 ល្ងាច (PT) ថ្ងៃច័ន្ទទី 7 ខែសីហា។**

ឱកាសទទួលបានមូលនិធិនេះគឺបើកចំហសម្រាប់អោយកុលសម្ព័ន្ធ និងអង្គការកុលសម្ព័ន្ធ អង្គការមិនរកប្រាក់ចំណេញ ក្រុមសហគមន៍ ហើយនិងអាជីវកម្មដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍នៅក្នុងតំបន់ស្ទឹង Duwamish ។ ប្រភេទនៃគម្រោងការដែលមានសិទ្ធិដាក់ពាក្យសុំ រួមមានទាំង ប៉ុន្តែមិនត្រឹមតែកំណត់ចំពោះសិល្បៈនិងការនិទានរឿង ការអប់រំសហគមន៍ ការកសាងសមត្ថភាពអង្គការនិងសហគមន៍ ការត្រៀមខ្លួនសម្រាប់ការប្រែប្រួលអាកាសធាតុ ការកសាងជំនាញនិងការបណ្ដុះបណ្ដាលការងារ ហើយនិងការធ្វើផែនការនិងចក្ខុវិស្ស័យសហគមន៍។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមអំពីការជំនួយមូលនិធិនេះ ចង់ពិភាក្សាអំពីគំនិតបើកគម្រោងការ ឬការដាក់ពាក្យសុំ អ្នកអាចអនុវត្តតាមជំហានដូចខាងក្រោម៖

- ចុះឈ្មោះនៅ **ទីនេះ** ដើម្បីពិភាក្សាតាមទូរសព្ទរយៈពេល 30 នាទីជាមួយសមាជិកនៃក្រុមការងាររបស់យើង។
    - *សូមប្រើទម្រង់បែបបទដើម្បីស្នើសុំសេវាកម្មបកប្រែភាសា។*

- ចូលរួមវគ្គផ្ដល់ព័ត៌មានតាមអនឡាញ៖
    - ថ្ងៃទី 21 ខែមិថុនា ម៉ោង 3:30-4:30 រសៀល - ចុះឈ្មោះនៅទីនេះ
    - *សូមផ្ញើអ៊ីមែលមកយើងតាមរយៈ DROF@seattle.gov ដើម្បីស្នើសុំសេវាកម្មបកប្រែភាសាជាមុន។*

- អ៊ីមែល DROF@seattle.gov

សូមចូលទៅកាន់ **seattle.gov/environment/DROF** ដើម្បីស្វែងយល់បន្ថែមហើយនិងដាក់ពាក្យសុំ។